ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

# សាលដីកា
## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

**សវនាព្រហ្មទណ្ឌ**
**សំណុំរឿងព្រហ្មទណ្ឌ**
លេខ ១១៤
ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩
**សាលដីកា**
លេខ ១៨ VII
ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២០

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម៖

១.ឯកឧត្តម [redacted] ប្រធាន
២.លោក [redacted] ចៅក្រម
៣.លោក [redacted] ចៅក្រម
៤.លោកស្រី [redacted] ចៅក្រម
៥.លោក [redacted] ចៅក្រមរបាយការណ៍

## ក្រឡាបញ្ជីសវនាការ

-លោក [redacted]

## តំណាងមហាអយ្យការ

-ឯកឧត្តម [redacted] អគ្គព្រះរាជអាជ្ញារង

## ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ៩៣ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩ របស់លោក [redacted] ពៅ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សាយយាង ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ១៣១ ក្រ.ៗ សវ.ៗ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមាន៖

Scanned with CamScanner

១.ជនជាប់ចោទឈ្មោះ [redacted] សាយយាង ហៅ [redacted] សាយយាង ភេទប្រុស អាយុ៤៨ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន [redacted] រាជធានីភ្នំពេញ ។ (អ្នកប្តឹងសាទុក្ខ)

មានមេធាវីការពារសិទ្ធិដោយ ៖ លោក [redacted] ហុកឆាយ

២.ជនជាប់ចោទឈ្មោះ [redacted] ហ៊ុន ភេទស្រី អាយុ៧៣ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន [redacted] រាជធានីភ្នំពេញ ។

មានមេធាវីការពារសិទ្ធិដោយ ៖ លោក [redacted] ហុកឆាយ

ជាប់ចោទពីបទៈ ប្រើប្រាស់លិខិតក្លែង និងបង្វែរវត្ថុបំអួស ឬវត្ថុដាក់ធានា ប្រព្រឹត្តនៅចំណុច រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦២៨ និងមាត្រា ៣៩៧ នៃក្រមព្រហ្មទណ្ឌ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ថា ភេទប្រុស អាយុ ៥៤ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន [redacted] ខេត្តព្រះសីហនុ ។

មានមេធាវីតំណាងដោយអាណត្តិ ៖ ១.លោក [redacted] សុផល
២.លោក [redacted] សុជាត
៣.លោក [redacted] នឿន

**១.អំពីអង្គហេតុ:**

កាលពីអំឡុង ឆ្នាំ១៩៩៧ នៅចំណុចរាជធានីភ្នំពេញមានករណីប្រើប្រាស់លិខិតឯកជនក្លែងមួយកើតឡើង ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] សាយយាង ហៅ [redacted] សាយយាង និងឈ្មោះ [redacted] ហ៊ុន បានធ្វើសកម្មភាពក្លែងលិខិតឯកជនរបស់ក្រុមហ៊ុន ម៉េង ស្រ៊ាង អ៊ិចស្រ្តេស នីហរ័ណ ដឹងជញ្ជូន ដោយនៅពេលដែលឪពុករបស់ជនរងគ្រោះ ឈ្មោះ [redacted] ភេទប្រុស អាយុ ៨៤ឆ្នាំ អំឡុងពេលធ្លាក់ខ្លួនឈឺធ្ងន់ឆ្លៀតឱកាសនោះឈ្មោះ [redacted] សាយយាង ហៅ [redacted] សាយយាង និងឈ្មោះ [redacted] ហ៊ុន បានធ្វើលិខិតក្លែងក្លាយមួយថា ជនរងគ្រោះឈ្មោះ [redacted] ចន្ថា និងប្អូនប្រុសឈ្មោះ [redacted] ចាន់សុខ លាលែងឈប់ពីក្រុមហ៊ុនប្រគល់ភាគហ៊ុនឱ្យទៅឈ្មោះ [redacted] សាយយាង ហៅ [redacted] សាយយាង ទាំងអស់ ហើយពេលនោះឈ្មោះ [redacted] សាយយាង ទៅចុះកុងត្រាករស៊ីជាមួយក្រុមហ៊ុនម៉ាឡេស៊ីមួយ ដោយលាក់កំបាំងពុំឱ្យអ្នកផ្សេងដឹងឡើយ ។ ក្រោយមកជនរងគ្រោះបានប្តឹងឈ្មោះ [redacted] សាយយាង ហៅ [redacted] សាយយាង ពីបទក្លែងបន្លំលិខិតឯកជន ហើយនគរបាលក្រសួងមហាផ្ទៃបានធ្វើកោសល្យវិច័យ ឃើញថា ឯកសារទាំងនោះ គឺជាលិខិតក្លែងក្លាយមែន ហើយចាប់ពីក្លែងលិខិតនេះរហូតមក ឈ្មោះ [redacted] សាយយាង ហៅ [redacted] សាយយាង បានប្រើប្រាស់លិខិតក្លែងនោះជាមធ្យោបាយក្នុងការបន្លំយកទ្រព្យរបស់ជនរងគ្រោះមកដល់សព្វថ្ងៃ ។ ជន

Scanned with CamScanner

រងគ្រោះក៏បានដាក់ពាក្យបណ្ដឹងចូលសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចេញដីកាសម្រេចតាមពាក្យសុំនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០១ ហើយពេលនោះសាលាដំបូងរាជធានីភ្នំពេញ បានចេញដីកាសម្រេចតាមពាក្យសុំលេខ ៥០ "ក" ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០១ រួចជនរងគ្រោះបានសុំអនុវត្តតាមពាក្យសុំចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០ ទៅអាជ្ញាធរខណ្ឌក្រសួងពាណិជ្ជកម្ម និងសុរិយោដី ប៉ុន្តែនៅឆ្នាំ២០១៣ ទើបជនរងគ្រោះដឹងថា ទ្រព្យដែលជានាក្នុងការរឹបអូសដែលមានចែងកត់ត្រា និងហាមឃាត់ ក្នុងដីកាសម្រេចតាមពាក្យសុំលេខ ៥០ "ក" ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០១ ត្រូវបានជនជាប់ចោទចាត់ចែងស្ទើរតែអស់រលីង ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៣៦៨ "អ" ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១. ចាត់របៀបលើសំណុំរឿងព្រហ្មទណ្ឌលេខ ៥៥០៥ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ដើម្បីវាយតម្លៃចលនវត្ថុ និងអចលនវត្ថុ តាមពាក្យសុំចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ របស់មេធាវី [redacted] សុផល ជាអ្នកតំណាងដោយអាណត្តិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី ។

២. ចាត់តាំងលោក [redacted] ជាចៅក្រមទទួលបន្ទុកចាត់ការបន្ត ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៨ កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី និងជនជាប់ចោទ ប្រកាសជាសាធារណៈនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១៧០១ "អ" ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១. ផ្ដន្ទាទោសលើ ៖

ក.ឈ្មោះ [redacted] សាយយាង ហៅ [redacted] សាយយាង ភេទប្រុស អាយុ៤៨ឆ្នាំ ។

ខ.ឈ្មោះ [redacted] ហ៊ុន ភេទស្រី អាយុ៧៣ឆ្នាំ ។

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ០១(មួយ)ឆ្នាំ ។

ពីបទ ប្រើប្រាស់លិខិតក្លែង និងបង្វែរវត្ថុរឹបអូស ឬវត្ថុដាក់ធានា ប្រព្រឹត្តនៅចំណុច រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៦២៨ និងមាត្រា ៣៩៧ នៃក្រមព្រហ្មទណ្ឌ ។

២. បង្គាប់ឱ្យឈ្មោះ [redacted] សាយយាង ហៅ [redacted] សាយយាង និងឈ្មោះ [redacted] ហ៊ុន រួមគ្នាសងសំណងខូចខាតផលប្រយោជន៍ និងទ្រព្យសម្បត្តិ ព្រមទាំងជម្ងឺចិត្ត សរុបចំនួន ៤.០០០.០០០(បួនលាន) ដុល្លារអាមេរិក ឱ្យទៅឈ្មោះ [redacted] ចន្ថា ជាដើមបណ្ដឹងរដ្ឋប្បវេណី ។ ការទាមទារលើសពីនេះត្រូវបដិសេធចោល ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨ ចំពោះមុខមេធាវីការពារក្ដីឱ្យដើមបណ្ដឹងរដ្ឋប្បវេណី កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី និងជនជាប់ចោទ ប្រកាសជាសាធារណៈនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨ ។

Scanned with CamScanner

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៤៩៣ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៨ របស់ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៥៤៤ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៨ ប្តឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៧០១ " អ " ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ របស់ឈ្មោះ [redacted] សុផល ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ថា ត្រង់ចំណុចទី២ នៃសេចក្តីសម្រេច ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ១៣១ ក្រ.l " សវ " ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១. ទទួលបណ្តឹងឧទ្ធរណ៍លេខ ៤៩៣ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់ ។

២. ទទួលបណ្តឹងឧទ្ធរណ៍លេខ ៥៤៤ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៨ របស់លោក [redacted] សុផល មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

៣. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៧០១ "អ" ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការលើកលែងតែចំណុចទី២ នៃការបង្គាប់ឱ្យឈ្មោះ [redacted] សាយយាង និងឈ្មោះ [redacted] ហ៊ុន រួមគ្នាសងសំណងខូចខាតផលប្រយោជន៍ និងទ្រព្យសម្បត្តិ ព្រមទាំងជម្ងឺចិត្តសរុបចំនួន ៤.០០០.០០០ (បួនលាន) ដុល្លារអាមេរិក ត្រូវកែប្រែទៅជា ៤០.៤១៨.៤០០ (សែសិបលានបួនសែនមួយម៉ឺនប្រាំបីពាន់បួនរយ) ដុល្លារអាមេរិក វិញ ។ ចំណុចផ្សេងទៀត នៃសាលក្រមនេះត្រូវរក្សាទុកជាបានការដដែល ។

សាលដីកានេះ ជំនុំជម្រះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សាយយាង និងឈ្មោះ [redacted] ហ៊ុន និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ។

ទុកសិទ្ធិប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ៩៣ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩ របស់លោក [redacted] ពៅ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សាយយាង ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ១៣១ ក្រ.l " សវ " ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

-បានឃើញ សារណាការពារ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ របស់លោក [redacted] ពៅ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សាយយាង ។

-បានឃើញ សារណាតប ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់លោក [redacted] សុផល និងលោក [redacted] នឿន ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ថា ។

Scanned with CamScanner

២.នាពេលសវនាការ

-បានស្តាប់ចៅក្រមបានអានរបាយការណ៍ ។

-បានស្តាប់តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានថា អំពីទម្រង់ច្បាប់បណ្តឹងសាទុក្ខលេខ ៩៣ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩ របស់លោក [redacted]៧ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]សាយយ៉ាង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ អំពីគតិច្បាប់ យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៩៣ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩ របស់មេធាវី [redacted] ៧ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]សាយយ៉ាង ពុំទាន់ផុតអាជ្ញាយុកាលទេ ដោយហេតុការជូនដំណឹងពីសាលដីកាសាលាឧទ្ធរណ៍ ពុំបានដល់ដៃជនជាប់ចោទ ឬអ្នកតំណាងរបស់ជនជាប់ចោទ ឬទៅបិទនៅលំនៅដ្ឋានរបស់ជនជាប់ចោទ ដែលផ្ទុយនឹងបញ្ញត្តិមាត្រា ៤៨៥ មាត្រា ៤៨៦ មាត្រា ៤៨៧ និងមាត្រា ៤៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ យល់ឃើញថា តុលាការអង្គសេចក្តីបានសម្រេចផ្តន្ទាទោសជនជាប់ចោទ លី សាយយ៉ាង ដាក់ពន្ធនាគារ ០១(មួយ)ឆ្នាំ ពីបទប្រើប្រាស់លិខិតក្លែង និងបទបង្វិលវត្ថុបែអូសឬវត្ថុដាក់ធានា តាមបញ្ញត្តិមាត្រា ៦២៨ និងមាត្រា ៣៩៧ នៃក្រមព្រហ្មទណ្ឌ ពុំត្រឹមត្រូវទេ ដោយហេតុថា បទល្មើសប្រើប្រាស់លិខិតក្លែង បានប្រព្រឹត្តនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ១៩៩៧ និងថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០១ ហើយដើមបណ្តឹងរដ្ឋប្បវេណី បានប្តឹងនៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៦ បើគិតរយៈពេល គឺផុតអាជ្ញាយុកាលហើយ ។ ចំណែក បទបង្វែរវត្ថុបែអូស ឬវត្ថុដាក់ធានា ប្រព្រឹត្តនៅអំឡុងឆ្នាំ២០០១ ឯមាត្រា ៣៩៧ នៃក្រមព្រហ្មទណ្ឌ បានចូលជាធរមាននៅឆ្នាំ ២០០៩ ដូចនេះអំពើរបស់ជនជាប់ចោទនៅពេលនោះច្បាប់ពុំទាន់បានបញ្ញត្តិជាបទព្រហ្មទណ្ឌនៅឡើយទេ ។ ដូច្នេះតំណាងមហាអយ្យការ សូមទុកជូនក្រុមប្រឹក្សាជំនុំជម្រះ ពិចារណា និងសម្រេចតាមច្បាប់ ។

-លោក [redacted] ហុកឆាយ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សាយយ៉ាង ហៅ [redacted] សាយយ៉ាង បានធ្វើសេចក្តីសន្និដ្ឋានថា កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៦ ឈ្មោះ [redacted] ចន្ថា បានប្តឹងកូនក្តីខ្លួនឈ្មោះ [redacted]សាយយ៉ាង ហៅ [redacted]សាយយ៉ាង និងឈ្មោះ [redacted] ហ៊ុន ពីបទប្រើប្រាស់លិខិតក្លែង និងបង្វែរវត្ថុបែអូសឬដាក់ធានា ប្រព្រឹត្តនៅរាជធានីភ្នំពេញ ដោយបានសំអាងលើកំណត់ហេតុប្រជុំ ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ១៩៩៧ និងទី២ គឺបង្កើតលក្ខន្តិកៈថ្មី ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០១ ដោយអះអាងថា កូនក្តីខ្លួន បានយកទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនឪពុករបស់ខ្លួនមកធ្វើជាទ្រព្យសម្បត្តិរបស់កូនក្តីខ្លួនទៅវិញ និងបានស្នើសុំឱ្យតុលាការផ្តន្ទាទោសកូនក្តីខ្លួនតាមច្បាប់ ។ នៅក្នុងសំណុំរឿងនេះ សាលាដំបូងរាជធានីភ្នំពេញ និងសាលាឧទ្ធរណ៍ បានសម្រេចផ្តន្ទាទោសកូនក្តីខ្លួនទាំងពីរនាក់ ព្រមទាំងបង្គាប់ឱ្យសងសំណងខូចខាតប្រយោជន៍ និងទ្រព្យសម្បត្តិ ព្រមទាំងជំងឺចិត្ត តាមសាលក្រមព្រហ្មទណ្ឌលេខ ១៧០១ (អ) ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ និងសាលដីកាព្រហ្មទណ្ឌលេខ ១៣១ ក្រ| សវ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ដូចមានខ្លឹមសារទាំងមូលស្រាប់ ។ ការសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញ និងសាលាឧទ្ធរណ៍នេះ ពុំបានពិនិត្យទៅលើអាជ្ញាយុកាលនៃបទល្មើសឡើយ ។ សរុប

Scanned with CamScanner

សេចក្ដីមក ការសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញ និងសាលាឧទ្ធរណ៍ ដែលបានសម្រេចអំពីអង្គហេតុដែលឈ្មោះ [redacted] ចន្ថា បានប្ដឹងនោះ គឺផ្ទុយនឹងអង្គច្បាប់ ។ ផ្អែកតាមពាក្យបណ្ដឹងរបស់ឈ្មោះ [redacted] ចន្ថា ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៦ ក៏ដូចជាសាលក្រមព្រហ្មទណ្ឌលេខ ១៧០១ (អ) ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ និងសាលដីកាព្រហ្មទណ្ឌលេខ ៤១១ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ឃើញថា ពុំបានពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយទៅលើអាជ្ញាយុកាលនៃបទល្មើសឡើយ ព្រោះថាពាក្យបណ្ដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានប្ដឹងចោទប្រកាន់កូនក្ដីខ្លួនទាំងពីរនោះ ផ្អែកលើកំណត់ហេតុប្រជុំ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ១៩៩៧ និងទី២- បង្កើតលក្ខន្តិកៈថ្មី ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០១ ប្រសិនបើគិតពីរយៈពេលពីថ្ងៃកំណត់ហេតុប្រជុំ និងបង្កើតលក្ខន្តិកៈថ្មីនោះ គឺផុតអាជ្ញាយុកាលនៃបណ្ដឹង ស្របតាមបញ្ញត្តិមាត្រា ១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងថិរវេលានៃអាជ្ញាយុកាល ត្រូវចាប់ផ្ដើមគិតពីពេលដែលប្រព្រឹត្តបទល្មើស ស្របតាមបញ្ញត្តិមាត្រា ១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ មួយវិញទៀត ដើមបណ្ដឹងរដ្ឋប្បវេណី បានដាក់ពាក្យសុំដីការក្សាការពារ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០១ ហើយសាលាដំបូងរាជធានីភ្នំពេញបានចេញដីកាសម្រេចរក្សាការពារតាមពាក្យសុំលេខ ០៥ (ក) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០១ និងបានដាក់ពាក្យសុំអនុវត្តដីកាសម្រេចរក្សាការពារ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០ ។ ត្រង់ចំណុចនេះ គឺដើមបណ្ដឹងរដ្ឋប្បវេណី បានដឹងអំពីវិវាទផ្ទៃក្នុងក្រុមហ៊ុនរបស់ខ្លួនតាំងពីឆ្នាំ២០០១ មកម្ល៉េះ ចុះហេតុអ្វីបានជាទើបតែប្ដឹងចោទប្រកាន់មកកូនក្ដីខ្លួនក្នុងរឿងព្រហ្មទណ្ឌនៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៦ ទៅវិញ ។ ខ្លួនស្នើសុំឱ្យ ឯកឧត្តមប្រធាន និងក្រុមប្រឹក្សាជំនុំជម្រះ មេត្តាពិនិត្យចំណុចនេះ ព្រោះថាសកម្មភាពបណ្ដឹងនេះផ្ទុយនឹងបញ្ញត្តិមាត្រា ១០ និងមាត្រា ១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ដោយឡែក លិខិតជូនដំណឹងអំពីសាលដីកាកំបាំងមុខរបស់សាលាឧទ្ធរណ៍ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ គឺកូនក្ដីខ្លួនទាំងពីរនាក់ ពុំដែលបានទទួលទាល់តែសោះ រួមទាំងសាច់ញាតិឬបងប្អូនក៏ពុំដែលបានទទួលលិខិតជូនដំណឹងអំពីសាលដីកាកំបាំងមុខដែរ ។ និយាយរួម ការបញ្ជូនរបស់មន្ត្រីអាជ្ញាសាលាធ្វើឡើងមិនត្រឹមត្រូវតាមបញ្ញត្តិមាត្រា ៤៨៥ មាត្រា ៤៨៦ និងមាត្រា ៤៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ ។ ដូចនេះ ត្រង់ចំណុចនៃការបញ្ជូនលិខិតជូនដំណឹងអំពីសាលដីកាកំបាំងមុខនេះ ខ្លួនស្នើសុំឱ្យ ក្រុមប្រឹក្សាជំនុំជម្រះ មេត្តាពិនិត្យតាមកំណត់ច្បាប់ ។ ចំណែកបណ្ដឹងសាទុក្ខដែលធ្វើឡើងដោយមេធាវីការពារសិទ្ធិរបស់កូនក្ដីខ្លួន គឺជាបណ្ដឹងធ្វើឡើងក្នុងកំណត់ច្បាប់ ព្រោះថា កូនក្ដីខ្លួន បានដឹងអំពីសេចក្ដីជូនដំណឹងអំពីសាលដីកាកំបាំងមុខនៅអំឡុងដើមខែមេសា ទើបនៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៩ បានប្ដឹងសាទុក្ខប្រឆាំងនឹងសាលដីការបស់សាលាឧទ្ធរណ៍នេះ ។ ដោយស្របតាមបញ្ញត្តិនៃមាត្រា ១០ និងមាត្រា ១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឃើញថា សកម្មភាពបណ្ដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៦ គឺធ្វើឡើងផុតកំណត់ច្បាប់ ដែលមិនអាចប្ដឹងទាមទារសិទ្ធិ និងផលប្រយោជន៍របស់ខ្លួនបាននោះទេ ។ ខ្លួនចង់បញ្ជាក់ដែរថា ពាក់ព័ន្ធទៅនិងការបញ្ជូន គឺមន្ត្រីអាជ្ញាសាលាធ្វើការបញ្ជូនខុសអាសយដ្ឋានទៅក្រុមហ៊ុនចាស់ អាសយដ្ឋានកូនក្ដីខ្លួនមិនមែនស្ថិតនៅទីតាំងដែលមន្ត្រីអាជ្ញាធ្វើការបញ្ជូននោះទេ ជាក់ស្ដែងកូនក្ដីខ្លួនមានអាសយដ្ឋាននៅផ្ទះលេខ ៥៣ ផ្លូវលេខ១៨៤ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។ ចំណុចទី២ មេធាវីតំណាងឱ្យដើម

Scanned with CamScanner

បណ្ដឹងរដ្ឋប្បវេណី បានលើកឡើងថាបានស្នើសុំឱ្យមានការផ្សព្វផ្សាយជាសាធារណៈ ក៏ដូចជានៅសាលាសង្កាត់ និងវិទ្យុជាដើម ដូច្នេះសួរថាការបិទផ្សព្វផ្សាយនេះអាចសន្មត់ថាកូនក្ដីខ្លួនបានទទួលព័ត៌មានពីលិខិតជូនដំណឹងអំពីសាលក្រមកំបាំងមុខដែរឬទេ ។ រហូតមកដល់ដើមខែមេសា ឆ្នាំ២០១៩ ទើបកូនក្ដីខ្លួនបានទទួលដំណឹងអំពីសាលក្រមកំបាំងមុខនេះ ទើបក្រោយមកកូនក្ដីខ្លួនធ្វើបណ្ដឹងសាទុក្ខ ។ ចំពោះសាលដីកាសាលាឧទ្ធរណ៍ដែលថាចូលជាស្ថាពរនេះគឺបានបំពានច្បាប់ ព្រោះថាសាលដីកានេះមិនបានចូលជាស្ថាពរនោះទេ ព្រោះអំឡុងដើមខែមេសា ឆ្នាំ២០១៩ កូនក្ដីខ្លួនបានដឹងអំពីសាលដីកាកំបាំងមុខនេះ ហើយកូនក្ដីខ្លួនមិនបានប្ដឹងទាស់នោះទេ តែកូនក្ដីខ្លួនមានសិទ្ធិប្ដឹងសាទុក្ខមកតុលាការកំពូល ដូច្នេះហើយរយៈពេលនៃការប្ដឹងសាទុក្ខនៅតែស្ថិតនៅក្នុងរយៈពេលកំណត់ច្បាប់ដដែល ។ ចំណុចទី៣ ខ្លួនក៏ចង់បញ្ជាក់ផងដែរថាស្នាមមេដៃនេះ ពិតជាស្នាមដៃរបស់កូនក្ដីខ្លួនពិតប្រាកដមែន ។ ខ្លួនសូមឱ្យ ឯកឧត្តមប្រធាន បដិសេធសាលដីកាព្រហ្មទណ្ឌលេខ ១៣១ ក្រ. សរ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ចោល និងសុំឱ្យកូនក្ដីខ្លួនទាំងពីរនាក់រួចផុតពីបទចោទ ។

-លោក [redacted] សុផល ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ថាបានធ្វើសេចក្ដីសន្និដ្ឋានថា កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ១៩៩៧ ឈ្មោះ [redacted] សាយយាង ហៅ [redacted] សាយយាង និងឈ្មោះ [redacted] ហ៊ុន ដែលត្រូវជាម្ដាយនិងកូនបានធ្វើកំណត់ហេតុប្រជុំវិសាមញ្ញមួយ ដែលថាឈ្មោះ [redacted] ចាន់សុខ និងឈ្មោះ [redacted] ស្រ៊ាង លាលែងឈប់ពីក្រុមហ៊ុនហើយប្រគល់ភាគហ៊ុននិងដីទៅឱ្យឈ្មោះ [redacted] សាយយាង និងឈ្មោះ [redacted] ហ៊ុន ទាំងអស់ ។ ក្រោយពីកូនក្ដីខ្លួនបានដឹងអំពីការក្លែងនេះ ក៏បានប្ដឹងភ្លាមសុំដីកាសម្រេចរក្សាការពារ និងប្ដឹងទៅសាលាដំបូងរាជធានីភ្នំពេញដើម្បីពិនិត្យកោសលវិច័យទៅលើកិច្ចសន្យាប្រគល់ភាគហ៊ុននោះ ហើយលទ្ធផលឃើញថាស្នាមមេដៃរបស់កូនក្ដីខ្លួននោះគឺស្នាមមេដៃនិងហត្ថលេខាក្លែងក្លាយទាំងស្រុង ។ នៅក្នុងពេលដែលកូនក្ដីខ្លួនកំពុងប្ដឹងផ្ដល់គ្នានោះ ស្រាប់តែឈ្មោះ [redacted] សាយយាង និងឈ្មោះ [redacted] ហ៊ុន បានយកទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនដែលមានការហាមឃាត់រួចហើយ យកមកបង្វែរទៅដាក់ចូលក្រុមហ៊ុននៅក្នុងស្រុកនិងក្រៅស្រុករបស់ខ្លួនទៅវិញ ហើយយកទ្រព្យទាំងអស់នោះទៅបញ្ចាំនៅធនាគារវឌ្ឍនៈ និងធនាគារកាណាឌីយ៉ា ក្រោយមកដោយឈ្មោះ [redacted] សាយយាង មិនមានប្រាក់សងទៅធនាគារ ទើបធនាគារទាំងអស់នោះរឹបអូសយកទ្រព្យសម្បត្តិទាំងអស់ទៅជាទ្រព្យសម្បត្តិរបស់ធនាគារ ដោយទ្រព្យសម្បត្តិទាំងអស់នោះមាន ៩ ប័ណ្ណ ។ ការដែលកូនក្ដីខ្លួនប្ដឹងពីបទប្រើប្រាស់លិខិតក្លែងនេះ គឺស្ថិតនៅក្នុងអាជ្ញាយុកាលដែលច្បាប់កំណត់ ព្រោះថាជនជាប់ចោទក្លែងហើយបានយកមកប្រើប្រាស់អូសបន្លាយពេលរហូតមកដល់ពេលបច្ចុប្បន្ន មានន័យថាបទល្មើសនេះមិនអាចផុតអាជ្ញាយុកាលបាននោះទេ ។ ទាក់ទងទៅនិងការសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញសម្រេចទៅលើសំណងត្រឹមតែ ៤.០០០.០០០ (បួនលាន) ដុល្លារអាមេរិក ចំណែកឯសាលាឧទ្ធរណ៍ បែរជាសម្រេចសំណងដល់ទៅ ៤០.០០០.០០០ (សែសិបលាន) ដុល្លារអាមេរិក ដោយមូលហេតុថាគឺមានការវាយតម្លៃពីក្រុមហ៊ុនឯករាជ្យមួយ ដោយការវាយតម្លៃទៅលើព្យសនកម្មដែលបាត់បង់ដូចនៅក្នុងប័ណ្ណកម្មសិទ្ធិទាំងអស់នោះ បើគិត

Scanned with CamScanner

ទៅជាង ៤០.០០០.០០០ (សែសិបលាន) ដុល្លារអាមេរិកដូចការសម្រេចរបស់សាលាឧទ្ធរណ៍ ។ ក្រោយពីសាលាឧទ្ធរណ៍បានប្រកាសនិងចេញសាលដីការួច សាលាឧទ្ធរណ៍បានជូនដំណឹងទៅជនត្រូវចោទតាមនីតិវិធី ដោយតាមរយៈសារព័ត៌មាន (កាសែតកោះសន្តិភាព និងរស្មីកម្ពុជា) វិទ្យុជាតិ និងព្រមទាំងបិទផ្សាយនៅអាសយដ្ឋានរបស់ក្រុមហ៊ុន ផ្ទះលេខ៣៥៧ ផ្លូវលេខ១២៨ (ផ្លូវកម្ពុជាក្រោម) ទីតាំងចាស់របស់ក្រុមហ៊ុន ។ សូមបញ្ជាក់ផងដែរថាឈ្មោះ [redacted] សាយយាង និងឈ្មោះ [redacted] ហ៊ុន ក្រោយពីបានក្លែងលិខិតហើយ ក៏បានរត់គេចខ្លួនបាត់តែម្តង ហើយពុំដែលចូលខ្លួនតាមរាល់ការកោះហៅនោះទេ ។ ចំពោះការប្រគល់សិទ្ធិឱ្យសហភាគា គឺឃើញមានតែស្នាមមេដៃរបស់ឈ្មោះ [redacted] សាយយាង តែប៉ុណ្ណោះ ហើយពុំមានឃើញបញ្ជាក់ថាស្នាមមេដៃនោះផ្តិតនៅទីណានោះទេ ដូច្នេះមានការសង្ស័យថាស្នាមមេដៃនោះពិតជាស្នាមេដៃរបស់ឈ្មោះ [redacted] សាយយាង ពិតឬយ៉ាងណា ។ ទាក់ទងទៅនិងការអវត្តមានរបស់ជនជាប់ចោទទាំងពីរនេះ ចាត់ទុកថាបណ្តឹងសាទុក្ខរបស់គាត់ជាអសារឥតការដូចបណ្តឹងទាស់ដែរឬទេ ខ្លួនយល់ឃើញថាប្រសិនបើជនជាប់ចោទប្តឹងសាទុក្ខហើយមិនបានចូលខ្លួនក្នុងសវនាការទេ នេះក៏ចាត់ទុកជាបណ្តឹងអសារឥតការផងដែរ ។ ចំណែកឯបណ្តឹងសាទុក្ខរបស់ឈ្មោះ លី សាយយាង មិនត្រឹមត្រូវទេ បើគិតពីពេលបិទផ្សាយរហូតផុតបណ្តឹងទាស់ រយៈពេល ១៥ថ្ងៃ ហើយរហូតមកផុតបណ្តឹងសាទុក្ខរហូតដល់ ១ខែ ១១ថ្ងៃ ទើបជនជាប់ចោទប្រគល់សិទ្ធិឱ្យមេធាវីប្តឹងសាទុក្ខនិងសាលដីកានេះ ខ្លួនយល់ឃើញថា បើសាលដីការបស់សាលាឧទ្ធរណ៍បានចូលជាស្ថាពររួចហើយ បានន័យថាអាជ្ញាអស់ជំនុំហើយ ហើយបើជាអាជ្ញាអស់ជំនុំគឺមិនអាចជំនុំជម្រះបានទៀតទេ ខ្លួនក៏បានដាក់ពាក្យសុំបដិសេធនៅបណ្តឹងសាទុក្ខរបស់ឈ្មោះ [redacted] សាយយាង ចោលជាអសារបង់មកតុលាការកំពូលរួចហើយ ។ ដូច្នេះខ្លួនសុំឱ្យតុលាការ តម្កល់សាលដីកា របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូលដដែល និងសុំឱ្យតុលាការបដិសេធបណ្តឹងសាទុក្ខរបស់ជនជាប់ចោទឈ្មោះ [redacted] សាយយាង ចោលទុកជាអសារបង់ ។

-លោក [redacted] នឿន ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ថា បានធ្វើសេចក្តីសន្និដ្ឋានថា ទាក់ទងទៅនិងចំណុចនៃការបញ្ជូន ដោយសារកន្លងមកជនជាប់ចោទធ្វើការគេចខ្លួន ហើយបិទទ្វារ ដូច្នេះមិនអាចបញ្ជូនឱ្យទៅជនជាប់ចោទដោយផ្ទាល់ដៃបាននោះទេ ប៉ុន្តែមានការបិទផ្សាយទៅតាមនីតិវិធី ព្រមទាំងមានចំណាររបស់អាជ្ញាសាលាផងដែរ ។ ចំណុចនេះហើយទើបក្នុងមាត្រា ៤១២ នៅពេលដែលការបញ្ជូនដោយផ្ទាល់ដៃមិនអាចធ្វើទៅបាន ទើបធ្វើការកំណត់អំពីរយៈពេលនៃការប្តឹងទាស់ទៅនិងសាលដីកាកំបាំងមុខរយៈពេល ១៥ថ្ងៃ ដោយគិតចាប់ពីថ្ងៃភាគីទទួលបានដំណឹងតាមរយៈការបញ្ជូនដោយផ្ទាល់ដៃ ប៉ុន្តែប្រសិនបើមិនបានបញ្ជូនដោយផ្ទាល់ដៃទេនោះ គឺគិតចាប់ពីថ្ងៃដែលពិរុទ្ធជនបានដឹងយ៉ាងពិតប្រាកដអំពីសាលដីកា ដូច្នេះមធ្យោបាយដែលធ្វើការបិទផ្សាយ និងផ្សព្វផ្សាយតាមវិទ្យុជាតិត្រូវបានចាត់ទុកថាជនជាប់ចោទបានដឹងយ៉ាងពិតប្រាកដ បើគិតមកដល់ពេលនេះ ប្រសិនបើជនជាប់ចោទមិនបានដឹងពិតមែន គឺជនជាប់ចោទមិនអាចមកប្តឹងបាននោះទេ ។ លើកចុងក្រោយដែលផ្សាយតាមវិទ្យុជាតិ នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩ បើគិតក្រោយរយៈពេល ១៥ថ្ងៃ ក្នុងការប្តឹងទាស់នោះ

Scanned with CamScanner

ត្រូវនិងថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៩ ប៉ុន្តែជនជាប់ចោទមិនបានធ្វើការប្ដឹងទាស់នោះទេ ។ ជនជាប់ចោទអាចធ្វើការប្ដឹង សាទុក្ខដោយគិតចាប់ពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០១៩ បាន ប៉ុន្តែជនជាប់ចោទមិនបានប្ដឹងសាទុក្ខទៀត រហូតមកដល់ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៩ ទើបជនជាប់ចោទធ្វើការប្ដឹងសាទុក្ខ ដូច្នេះហួសរយៈពេលក្នុងការប្ដឹងសាទុក្ខបាត់ទៅហើយ ។ ចំណុចទី២ ទាក់ទងទៅនិងអាជ្ញាយុកាលនៃបទល្មើស ខ្លួនសុំបដិសេធទៅរឿងដែលថាផុតអាជ្ញាយុកាល ព្រោះនៅក្នុងសំណុំរឿងចាស់ដែលបានប្ដឹងជាង ១០ឆ្នាំ មុននោះត្រូវបានបញ្ចប់ដោយមានវិការៈ ។ នៅឆ្នាំ២០០៦ ជនត្រូវចោទឈ្មោះ [redacted] សាយយាង បានលួងលោមកូនក្ដីខ្លួនឱ្យធ្វើលិខិតដកពាក្យបណ្ដឹង ដើម្បីបញ្ចប់សំណុំរឿងព្រហ្មទណ្ឌពីបទក្លែងលិខិតនោះ ក្នុងអត្ថន័យនៃការដកពាក្យបណ្ដឹងនេះដោយសំអាងលើមូលហេតុថាមានការញុះញង់ធ្វើឱ្យបងប្អូនស្អប់គ្នា ប៉ុន្តែអត្ថន័យពិតនោះគឺក្រោយធ្វើការបញ្ចប់រឿងហើយគឺមានការសម្រប សម្រួលដើម្បីធ្វើការបែងចែកទ្រព្យសម្បត្តិគ្នា ស្រាប់តែឈ្មោះ [redacted] សាយយាង នៅពេលដែលទទួលបានស្នាមមេដៃរបស់កូនក្ដីខ្លួនហើយ បែរជាមិនព្រមចែកទ្រព្យនោះមកឱ្យកូនក្ដីខ្លួនទៅវិញ ហើយការដកពាក្យ បណ្ដឹងនេះគឺធ្វើនៅសាលាឧទ្ធរណ៍ នៅពេលដែលសាលាឧទ្ធរណ៍ចេញសាលដីកាកំបាំងមុខមកលើកូនក្ដីខ្លួន កូនក្ដីខ្លួនក៏សម្រេចចិត្តប្ដឹងទាស់និងសាលដីការបស់សាលាឧទ្ធរណ៍ ។ ប៉ុន្តែដោយរឿងនេះមានរយៈពេលយូរពេក ខ្លួនបានព្យាយាមដាក់ពាក្យសុំលើករឿងឱ្យចាត់ការ តែនៅតែមិនអាចរកឃើញបានដោយសារតែមូលហេតុនេះហើយ ទើបខ្លួនយល់ថាពុំមានសេចក្ដីសម្រេចណាមួយដែលបង្អង់អាជ្ញាយុកាលនៃបទល្មើសក្លែងលិខិតនេះទេ ខ្លួននៅតែយល់ឃើញថាអាជ្ញាយុកាលនៃបទល្មើសក្លែងលិខិតនិងប្រើប្រាស់លិខិតក្លែង គឺតុលាការមិនទាន់បានសម្រេចបញ្ចប់នៅសំណុំរឿងចាស់នោះទេ ដោយសារតែខ្លួនមិនអាចរកឃើញសំណុំរឿងចាស់នេះបាន ទើបខ្លួនប្ដឹងទៅលើសំណុំរឿងថ្មីនេះ ពីបទប្រើប្រាស់លិខិតក្លែងនិងបង្វែរវត្ថុដែលត្រូវរឹបអូស ឬដាក់ធានា ។ នៅពេលដែលសាលាឧទ្ធរណ៍បានចេញសាលដីកា ខ្លួនបានស្នើសុំបញ្ជាក់ស្ថាពរ ហើយសាលាឧទ្ធរណ៍បានចេញសាលដីកាព្រមទាំងផ្ដល់រូបមន្តអនុវត្តនៅផ្នែកខាងក្រោមមកជាមួយឃើញថាសាលដីការបស់សាលាឧទ្ធរណ៍ដែលបានចូលជាស្ថាពររួចទៅហើយ ហេតុនេះតុលាការកំពូលពុំអាចទទួលជំនុំជម្រះបាននោះទេ ដោយមូលហេតុបណ្ដឹងសាទុក្ខនេះផុតកំណត់ច្បាប់ ។ ដូច្នេះខ្លួនសុំឱ្យតុលាការកំពូលពិចារណានិងសម្រេចរក្សាទុកនូវសាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍លេខ ១៣១ ក្រ.សវ.ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ ទុកជាបានការពេញទាំងមូល ។

-ក្រោយបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដីឱ្យជនជាប់ចោទ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់លោកមេធាវីការពារក្ដីឱ្យដើមបណ្ដឹងរដ្ឋប្បវេណី

Scanned with CamScanner

-ក្រោយបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-យល់ឃើញថា ការដែលសហាមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងក្នុងសារណាលាយ លក្ខណ៍អក្សរ ក៏ដូចជាសេចក្តីសន្និដ្ឋានផ្ទាល់មាត់នាពេលសវនាការពិភាក្សាដេញដោលនៅចំពោះមុខតុលាការកំពូល ដែរថាសាលដីកាព្រហ្មទណ្ឌកំបាំងមុខលេខ ១៣១ "ក្រ.សវ" ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ ២០១៨ របស់សភាព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ ដែលជាកម្មវត្ថុនៃការប្តឹងសាទុក្ខនាពេលនេះ បានចូលជាស្ថាពរហើយ ដែលសាលាឧទ្ធរណ៍បានចារ បញ្ជាក់ពីការចូលជាស្ថាពររួចហើយ ដោយហេតុថា បន្ទាប់ពីបានសម្រេចកំបាំងមុខជនជាប់ចោទ សាលាឧទ្ធរណ៍ក៏បានធ្វើនីតិវិធីជូនដំណឹងអំពីសេចក្តីសម្រេចកំបាំងមុខនេះទៅជនជាប់ចោទឈ្មោះ [redacted] សាយយាង តាមនីតិវិធី ច្បាប់ដូចជា ការផ្សាយតាមវិទ្យុជាតិ ចុះផ្សាយក្នុងទំព័រសារព័ត៌មាន បិទផ្សាយសាលដីកានៅនឹងផ្ទះលេខ ៣៩៥-៣៩៧ ផ្លូវកម្ពុជាក្រោម សង្កាត់មិត្តភាព ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ហេតុនេះ បណ្តឹងសាទុក្ខរបស់ភាគីជន ជាប់ចោទឈ្មោះ [redacted] សាយយាង ធ្វើឡើងខុសនឹងទម្រង់ច្បាប់ ដែលផុតរយៈពេលប្តឹងសាទុក្ខរហូតដល់ទៅ ៤០ ថ្ងៃ ឯណោះ នោះគឺជាអំណះអំណាងមិនត្រឹមត្រូវទេ ដោយមូលហេតុថា ៖

-តាមបទប្បញ្ញត្តិមាត្រា ៣៦៨ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០១៣ ស្តីពីរយៈ ពេលសម្រាប់ធ្វើបណ្តឹងទាស់ ត្រង់កថាខណ្ឌទី២ បានបញ្ញត្តថា "បណ្តឹងទាស់ត្រូវតែធ្វើនៅក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ផ្តើមគិតចាប់ពីថ្ងៃដែលពិរុទ្ធជននេះបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះ មិនបានប្រគល់ឱ្យដល់ពិរុទ្ធជនដោយផ្ទាល់ដៃទេ ។ ពិរុទ្ធជនត្រូវចាត់ទុកថាបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម ក្នុងករណីដែលនីតិវិធីនៃការឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងគន្ថីទី៧ មាតិកាទី៤ ស្តីពីដីកាឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការនៃក្រមនីតិវិធី ព្រហ្មទណ្ឌ។ ហើយដែនអនុវត្តនៃបទប្បញ្ញត្តិមាត្រា ៣៦៨ ថ្មីនេះ ត្រូវពន្លាតដល់សាលាឧទ្ធរណ៍ តាមបទប្បញ្ញត្តិ មាត្រា ៣៩៦ សីពីការពន្លាតដល់សាលាឧទ្ធរណ៍នូវវិធានដែលអនុវត្តចំពោះសាលាដំបូងនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-ពិនិត្យមើលលើចំណាត់ការនៃរឿងក្តីនេះជាអាទិ៍ ដីកាកោះហៅ ជាពិសេសកិច្ចនៃនីតិវិធីជូនដំណឹងអំពី សេចក្តីសម្រេចរបស់តុលាការ ដែលធ្វើឡើងដោយអាជ្ញាធរទទួលបន្ទុកការបញ្ជូនទៅភាគីជនជាប់ចោទ គឺបានធ្វើ លិខិតជូនដំណឹងដោយការបញ្ជូនទៅអាសយដ្ឋាន ផ្ទះលេខ ៣៩៥-៣៩៧ ផ្លូវកម្ពុជាក្រោម សង្កាត់មិត្តភាព ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ដែលជាអាសយដ្ឋានកំណត់ក្នុងពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជាអាសយដ្ឋាន ទីស្នាក់ការរបស់នីតិបុគ្គល ក្រុមហ៊ុន ម៉េងស្រ៊ាង អ៊ិចស្ព្រេសតាមលក្ខន្តិកៈឆ្នាំ១៩៩៧ និងអនុស្សរណៈ និងលក្ខន្តិកៈ ក្រុមហ៊ុនដឹកជញ្ជូន MSE KPM Co.LTD ឆ្នាំ២០០១ ដែលមិនមែនជាអាសយដ្ឋានរបស់រូបវន្តបុគ្គលឈ្មោះ [redacted] សាយយាង នោះទេ ហើយពាក់ព័ន្ធនឹងការចេញ

Scanned with CamScanner

ដីកាកោះហៅផ្សេងទៀត តាំងពីសាលដំបូងរាជធានីភ្នំពេញ រហូត ដល់សាលាឧទ្ធរណ៍ភ្នំពេញ ត្រូវបាន នគរបាលមូលដ្ឋាន ក៏ដូចជាអាជ្ញាធរដែនដីភូមិ-សង្កាត់ សុទ្ធតែបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] សាយយាង មិនដែលស្នាក់នៅក្នុងអាសយដ្ឋាន ក្នុងសង្កាត់មិត្តភាព ខណ្ឌ ៧ មករា នោះទេ ដែលទីតាំងនោះ គ្រាន់តែជាកន្លែងធ្វើពាណិជ្ជកម្មប៉ុណ្ណោះ ។

ផ្ទុយទៅវិញ តាមរយៈភស្តុតាងនានា ដូចជាឯកសាររបស់ក្រុមហ៊ុន រួមនឹងពាក្យសុំដកបណ្តឹងចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៦ ដែលធ្វើឡើងដោយឈ្មោះ [redacted] ចន្ថា ជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីនេះ និងឈ្មោះ [redacted] ចាន់សុខ សុទ្ធតែបង្ហាញថា ជនជាប់ចោទឈ្មោះ [redacted] សាយយាង មានទីលំនៅផ្សេងពីអាសយដ្ឋានទីស្នាក់ការរបស់ ក្រុមហ៊ុនខាងលើ និងតាមលិខិតពឹងពាក់មេធាវីរបស់ជនជាប់ចោទក្នុងនីតិវិធីប្តឹងសាទុក្ខនាពេលនេះ គាត់ក៏បានដាក់ អាសយដ្ឋានផ្ទាល់ខ្លួនដែលដូចគ្នានឹងអាសយដ្ឋានដែលគាត់ធ្លាប់បានប្រើប្រាស់ពីមុនៗមកផងដែរ ។ យោងតាម បទប្បញ្ញត្តិក្នុងគន្ថីទី៧ មាតិកាទី៤ ជំពូកទោល បញ្ញត្តអំពីដីកាឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការនៃក្រម នីតិវិធីព្រហ្មទណ្ឌ ជាពិសេសត្រង់បទប្បញ្ញត្តិមាត្រា ៤៨២ , ៤៨៦ , ៤៨៧ , ៤៨៨ និងមាត្រា ៤៨៩ កំណត់ថា កិច្ចជូនដំណឹងមានកម្មវត្ថុជូនដំណឹងដល់ភាគីពាក់ព័ន្ធឱ្យដឹងអំពីសេចក្តីសម្រេចរបស់តុលាការ ដែលក្នុងន័យនេះ លំនៅដ្ឋានរបស់បុគ្គលទទួលដំណឹងអំពីសេចក្តីសម្រេចគឺជាទីកន្លែងចាំបាច់ដែលត្រូវអនុវត្តនីតិវិធីនៃការជូនដំណឹង។ ករណីនេះ នីតិវិធីឱ្យដំណឹងរបស់មន្ត្រីសាលាឧទ្ធរណ៍ភ្នំពេញ ដែលធ្វើការបញ្ជូនលិខិតជូនដំណឹងអំពីសាលដីកា ព្រហ្មទណ្ឌកំបាំងមុខត្រឹមតែអាសយដ្ឋានជាទីស្នាក់ការក្រុមហ៊ុនដែលធ្វើពាណិជ្ជកិច្ច ដោយមិនបានបញ្ជូនកិច្ចនៃលិខិតជូនដំណឹងទៅដល់លំនៅដ្ឋានរបស់ជនជាប់ចោទផ្ទាល់ ស្របពេលជនជាប់ចោទមានអាសយដ្ឋានត្រឹមត្រូវ បែបនេះ គឺមិនមានលក្ខណៈគ្រប់គ្រាន់ និងមិនសមស្របតាមបទប្បញ្ញត្តិនីតិវិធីព្រហ្មទណ្ឌជាធរមានឡើយ ។ ដូច្នេះ បែបបទនៃការឱ្យដំណឹងនិងការអនុវត្តការប្រគល់លិខិតឱ្យជូនដំណឹង ធ្វើឡើង មិនស្របតាមបទប្បញ្ញត្តិនៃក្រម នីតិវិធីព្រហ្មទណ្ឌ ដូចលើកបង្ហាញខាងលើនេះឡើយ ។

តាមសំអាងហេតុខាងលើនេះ កិច្ចនៃការឱ្យដំណឹងរបស់សាលាឧទ្ធរណ៍ត្រឹមកម្រិតនេះ មិនអាចចាត់ទុកថា ពិរុទ្ធជនបានដឹងអំពីសេចក្តីសម្រេចនៃសាលដីកាព្រហ្មទណ្ឌលេខ១៣១ "ក្រ.សវ" ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ នោះ ទេ ។ ពិនិត្យជារួម ចំណាត់ការលើរឿងក្តីនេះ រួមទាំងសេចក្តីសម្រេចរបស់តុលាការអង្គសេចក្តីទាំងពីរថ្នាក់ផង ធ្វើ ឡើងកំបាំងមុខជនជាប់ចោទចាប់តាំងពីដើមដំបូងរហូតមក ដោយមិនបានគោរពនិងអនុវត្តនូវគោលការណ៍ចំពោះ មុខក្នុងរឿងក្តីព្រហ្មទណ្ឌនោះឡើយ ហេតុដូចនេះហើយ បានធ្វើឱ្យប៉ះពាល់សិទ្ធិនិងផលប្រយោជន៍ដល់ភាគីជនជាប់ ចោទឈ្មោះ [redacted] សាយយាង យ៉ាងធ្ងន់ធ្ងរ ។

ករណីក្នុងរឿងក្តីនេះ សាលដីកាព្រហ្មទណ្ឌលេខ ១៣១ "ក្រ.សវ" ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ របស់ សាលាឧទ្ធរណ៍ភ្នំពេញ ដែលជាកម្មវត្ថុនៃការប្តឹងសាទុក្ខ មិនទាន់ចូលជាស្ថាពរនៅឡើយទេ ហេតុនេះភាគីមានសិទ្ធិ និងផលប្រយោជន៍ពាក់ព័ន្ធ មានសិទ្ធិប្តឹងតវ៉ាតាមកំណត់ច្បាប់។

២-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៩៣ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩ របស់មេធាវី [redacted] ពៅ ជាមេធាវីទទួលសិទ្ធិតំណាងឱ្យជនជាប់ចោទឈ្មោះ [redacted] សាយយាង ក្នុងការប្តឹងសាទុក្ខ ធ្វើឡើងក្នុងកំណត់

Scanned with CamScanner

ច្បាប់តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងបទប្បញ្ញត្តិមាត្រា ៤១៧, មាត្រា ៤១៨ , មាត្រា ៤២០ និងមាត្រា ៤២២ ត្រង់កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-យល់ឃើញថា សំណុំរឿងក្តីនេះ សាលាដំបូងរាជធានីភ្នំពេញបានចេញសាលក្រមព្រហ្មទណ្ឌកំបាំងមុខ ជនជាប់ចោទចំនួនពីរនាក់ គឺឈ្មោះ [redacted]សាយយាង ហៅ [redacted]សាយយាង ភេទប្រុស អាយុ៤៨ ឆ្នាំ និងឈ្មោះ [redacted]ហ៊ុន ភេទស្រី អាយុ ៧៣ ឆ្នាំ ។ ឯបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយព្រះរាជអាជ្ញានិងភាគីដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែបណ្តឹងសាទុក្ខក្នុងរឿងក្តីនេះ ធ្វើឡើងដោយជនជាប់ចោទឈ្មោះ [redacted]សាយយាង តែម្នាក់ប៉ុណ្ណោះ។ ហេតុនេះ តាមបទបញ្ញត្តិមាត្រា ៤១៩ , មាត្រា ៤៣៦ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ បណ្តឹងសាទុក្ខនេះមាន អានុភាពអាចឱ្យតុលាការកំពូលពិនិត្យ ពិចារណា វិនិច្ឆ័យ សម្រេច ត្រឹមតែកម្រិតក្របខណ្ឌសិទ្ធិ និងផលប្រយោជន៍ របស់ជនជាប់ចោទឈ្មោះ [redacted]សាយយាង តែម្នាក់ប៉ុណ្ណោះ ។

៤-យល់ឃើញថា ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានតំណាងមហាអយ្យការអមតុលាការ កំពូលបានជូនដំណឹងអំពីកាលបរិច្ឆេទនៃថ្ងៃសវនាការ ពិភាក្សាដេញដោលត្រឹមត្រូវហើយ តែមិនមានវត្តមានចូល រួមនាពេលសវនាការពិភាក្សាដេញដោលនេះទេ តែបានដាក់សារណា និងមានមេធាវីរបស់គូភាគីចូលរួមសវនាការ ហើយ ដូច្នេះ តុលាការកំពូលអាចបន្តនីតិវិធីពិភាក្សាដេញដោលបាន ដោយផ្អែកតាមបទប្បញ្ញត្តិមាត្រា ៤៣៣ និងមាត្រា ៤៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៥-យល់ឃើញថា ការដែលតុលាការសាលាដំបូងរាជធានីភ្នំពេញ ក៏ដូចជាសាលាឧទ្ធរណ៍ដែរ ដែលបាន សម្រេច និងប្រកាសទោសលើជនជាប់ចោទឈ្មោះ [redacted]សាយយាង ហៅ [redacted]សាយយាង ពីបទប្រើប្រាស់លិខិត ក្លែងនិងបង្វែរវត្ថុរឹបអូសឬដាក់ធានា ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៣ បទល្មើសព្រហ្មទណ្ឌដែល មានចែងនិងឱ្យផ្តន្ទាទោសតាមបទប្បញ្ញត្តិមាត្រា ៦២៨ និងមាត្រា ៣៩៧ នៃក្រមព្រហ្មទណ្ឌ ដោយសំអាងហេតុ ថា ជនជាប់ចោទបានក្លែងហត្ថលេខារបស់ដើមបណ្តឹងរដ្ឋប្បវេណីលើកំណត់ហេតុអង្គប្រជុំ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ១៩៩៧ និងឯកសារជាតារាងអនុប្បទានភាគហ៊ុន ក្នុងឧបសម្ព័ន្ធទី១ នៃសេចក្តីសម្រេចសមូហភាពលេខ ០១/៩៧ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ១៩៩៧ ដែលការក្លែងនេះត្រូវបានបញ្ជាក់ដោយលិខិតកោសលវិច័យលេខ ០៣/០២ ហ.ខ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០២ របស់មន្ត្រីជំនាញ និងបានប្រើប្រាស់ឯកសារក្លែងទាំងនេះទៅបង្កើតលក្ខន្តិកៈថ្មី ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០១ ដើម្បីបង្វែរនិងគៃបំបាត់ទ្រព្យរបស់ក្រុមហ៊ុនដើម ព្រមទាំងជនជាប់ចោទបានចាត់ ចែងទ្រព្យសម្បត្តិទំនាស់មួយចំនួនដែលជាកម្មវត្ថុនៃដីកាសម្រេចតាមពាក្យសុំលេខ ៥០ "ក" ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០១ របស់សាលាដំបូងរាជធានីភ្នំពេញនោះ សេចក្តីសម្រេចនេះមិនត្រឹមត្រូវនោះទេ ដោយមូលហេតុ ៖

Scanned with CamScanner

-តាមអំណះអំណាងរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងឯកសារស្តីពីការដកពាក្យបណ្តឹង ជាច្រើនលើកក្នុងអំឡុងឆ្នាំ២០០៦ រវាងគូភាគីទំនាស់ នោះបង្ហាញថា អង្គហេតុនេះត្រូវបានគូភាគីប្តឹងគ្នាក្នុងនីតិវិធី តុលាការព្រហ្មទណ្ឌផងនិងតុលាការរដ្ឋប្បវេណី ។

-ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៨៩៨ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០១ របស់សាលាដំបូងរាជធានីភ្នំពេញ មានសាលក្រមកំបាំងមុខលេខ ៣២ "ង" ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៣ ដែលបានសម្រេចឱ្យជនជាប់ចោទ ឈ្មោះ [redacted] សាយយាង រួចផុតពីការចោទប្រកាន់បទរំលោភលើទំនុកចិត្តនិងក្លែងលិខិតឯកជន ដែលរឿងនេះមាន ភាគីដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ថា (ដែលជាភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីនេះ) និងឈ្មោះ [redacted] ចាន់សុខ ។ សាលក្រមកំបាំងមុខលេខ ៣២ "ង" ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៣ នេះ ត្រូវបានភាគីទាំងសងខាង ប្តឹងឧទ្ធរណ៍ ដោយមានសំណុំរឿងព្រហ្មទណ្ឌលេខ ៧៩២ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៣ ហើយសាលាឧទ្ធរណ៍បាន សម្រេចទៅតាមពាក្យសុំដកបណ្តឹងឧទ្ធរណ៍ក្នុងឆ្នាំ២០០៦ របស់គូភាគី ដូចមានក្នុងសម្រង់សាលដីកាព្រហ្មទណ្ឌ លេខ ០២ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៧ ដោយចំណាយសំណុំរឿងក្តីព្រហ្មទណ្ឌលេខ ៧៩២ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៣ ចេញពីបញ្ជីក្តី។ សាលដីកានេះត្រូវបានសហដើមបណ្តឹងរដ្ឋប្បវេណីប្តឹងទាស់និងប្តឹងសាទុក្ខ ។ ហើយបើ ពិនិត្យមើលលើពាក្យបណ្តឹងចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ឈ្មោះ [redacted] ចន្ថា ក្នុងរឿងក្តីនេះ ក៏គាត់បានអះ អាងថា ជនជាប់ចោទបានក្លែងលិខិតនិងប្រើប្រាស់លិខិតក្លែង ដើម្បីគៃបំបាត់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ដែល ភាគីខ្លួនក៏ធ្លាប់បានប្តឹងជនជាប់ចោទពីបទក្លែងលិខិតឯកជន ដោយភ្ជាប់ជាមួយនឹងលិខិតកោសល្យវិច័យរបស់ នគរបាលជំនាញនៃក្រសួងមហាផ្ទៃដែរ ។

-ឯក្នុងរឿងក្តីរដ្ឋប្បវេណីវិញ ជាពិសេសពិនិត្យលើដីកាសម្រេចតាមពាក្យសុំលេខ ៥០ "ក" ចុះថ្ងៃទី២៣ ខែ សីហា ឆ្នាំ២០០១ មានសំណុំរឿងរដ្ឋប្បវេណីអង្គសេចក្តីលេខ ៩៦០ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០១ របស់សាលា ដំបូងរាជធានីភ្នំពេញ និងសំណុំរឿងរដ្ឋប្បវេណីលេខ ៦៦៤ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍គឺ មានដើមចោទឈ្មោះ [redacted] ចន្ថា និងឈ្មោះ [redacted] ចាន់សុខ បានប្តឹងសុំមោឃៈនូវលក្ខន្តិកៈក្លែងក្លាយរបស់ក្រុមហ៊ុន ម៉េងស្រ៊ាង អ៊ិចស្ព្រេស, លក្ខន្តិកៈក្រុមហ៊ុនដឹកជញ្ជូន MSE KPM Co.LTD និងសុំគ្រប់គ្រងអាជីវកម្មតាមលក្ខន្តិកៈ ដើមវិញ។ ក្នុងដំណើរការនីតិវិធីរបស់សាលាឧទ្ធរណ៍ គូភាគីបានឯកភាពគ្នាបញ្ចប់វិវាទទាំងអស់ ដោយភាគីដើម ចោទឈ្មោះ [redacted] ចន្ថា និងឈ្មោះ [redacted] ចាន់សុខ សុំដកពាក្យបណ្តឹងឧទ្ធរណ៍ និងដកពាក្យបណ្តឹងទាំងអស់ដែលខ្លួន បានប្តឹងជនជាប់ចោទឈ្មោះ [redacted] សាយយាង ដូចមានខ្លឹមសារសំណោរក្នុងពាក្យសុំដកបណ្តឹងឧទ្ធរណ៍ និងពាក្យសុំ ដកបណ្តឹងចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់គូភាគី ។ ជាមួយនឹងដំណើរការនីតិវិធីក្នុងរឿងក្តីរដ្ឋប្បវេណីនេះ ជនជាប់ចោទឈ្មោះ [redacted] សាយយាង បានតាំងខ្លួនជាដើមចោទប្តឹងសុំឱ្យតុលាការទទួលស្គាល់នូវលក្ខន្តិកៈក្រុមហ៊ុនថ្មី ដោយកំណត់យកដើមបណ្តឹងឈ្មោះ [redacted] ចន្ថា និងឈ្មោះ [redacted] ចាន់សុខ ជាភាគីចុងចម្លើយក្នុងប

Scanned with CamScanner